# លក្ខខណ្ឌដាក់ពាក្យប្រឡងចម្រៀងណូដូជីម៉ាន់ឆ្នាំ២០១៩

## សេចក្តីណែនាំនៃការដាក់ពាក្យប្រឡង

- ការប្រឡងលើកនេះ គឺជាការប្រកួតប្រជែងរវាងសាលា និងសាលា។ សាលារៀនភាសាជប៉ុនណាដែលមានបំណងឲ្យកូនសិស្សចូលរួមប្រឡង សូមអញ្ជើញមកដាក់ពាក្យប្រឡង។
- ចំពោះចំនួនបេក្ខជនប្រឡងចម្រៀងទោល ឬ បេក្ខជនប្រឡងជាក្រុម តាមសាលានីមួយៗ នឹងត្រូវកំណត់ចំនួនដោយយោងទៅលើ ចំនួនសាលាសរុបចុងក្រោយដែលបានដាក់ពាក្យចូលរួម និងចំនួនសិស្សនៃសាលានីមួយៗនោះផងដែរ។
- បេក្ខជនដែលចូលរួមប្រកួតត្រូវត្រៀមភ្លេងសម្រាប់ច្រៀងនៅថ្ងៃប្រឡងដោយខ្លួនឯង ហើយត្រូវផ្ញើមកកាន់ស្ថានទូតមុនថ្ងៃប្រឡង។
- ការប្រឡងចម្រៀងលើកនេះ មិនដូចការប្រឡងលើកមុនៗដែលមានខារ៉ាអូខេអាចមើលឃើញតួរអក្សរចម្រៀងទេ បេក្ខជនត្រូវទន្ទេញបទចម្រៀងឲ្យបានចាំ ហើយច្រៀងលើឆាកតែម្តង។
- កម្មវិធីប្រឡងចម្រៀងណូដូជីម៉ាន់

| | |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃអាទិត្យ ទី១៤ ខែកក្កដា ឆ្នាំ២០១៩ |
| ពេលវេលាហាត់សម | ០៨:០០- ០៩:០០ |
| ពេលវេលាប្រឡងចម្រៀង | ០៩:៣០ -១២:០០ |

ការប្រឡងលើកនេះ រៀបចំឡើងនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ក្នុងឱកាសពិធីបុណ្យផ្កាយ (តាណាបាតា) ថ្ងៃទី១៣ និង ១៤ ខែកក្កដា ឆ្នាំ២០១៩។

**នីតិវិធីនៃការដាក់ពាក្យ**

១. ការចុះឈ្មោះចូលរួមរបស់សាលាភាសាជប៉ុននីមួយៗ (ផុតកំណត់ត្រឹមថ្ងៃសុក្រ ទី១៧ ខែឧសភា ឆ្នាំ២០១៩)

ពាក្យស្នើសុំចូលរួម អាចរកបានតាមរយៈគេហទំព័រខាងក្រោម៖

https://www.kh.emb-japan.go.jp/files/000469974.pdf

២. ការប្រកាសលទ្ធផលចំនួនបេក្ខជនច្រៀងទោល ឬ ជាក្រុម នៃសាលានីមួយៗ (ថ្ងៃច័ន្ទ ទី២៧ ខែឧសភា ឆ្នាំ២០១៩)

៣. ការផ្ញើពាក្យចូលរួមប្រឡងរបស់បេក្ខជនពីសាលានីមួយៗ (ផុតកំណត់ត្រឹមថ្ងៃសុក្រ ទី២១ ខែមិថុនា ឆ្នាំ២០១៩)

ពាក្យចូលរួមប្រឡងរបស់បេក្ខជនអាចរកបានតាមរយៈគេហទំព័រខាងក្រោម៖

https://www.kh.emb-japan.go.jp/files/000469976.pdf

៤. ការផ្ញើភ្លេងចម្រៀងពីបេក្ខជនចូលរួមប្រឡង (ផុតកំណត់ត្រឹមថ្ងៃសុក្រ ទី២៨ ខែមិថុនា ឆ្នាំ២០១៩)